**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គជអប
NCDD

## លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍រីកចំរើនប្រចាំឆ្នាំ២០១៧






**រៀបចំដោយ៖**

ក្រុមការងារសុវត្ថិភាព ប.ដ.ជ នៃលេខាធិការដ្ឋាន គ.ជ.អ.ប.

ខែធ្នូ ឆ្នាំ២០១៧

# មាតិកា


១. សេចក្តីផ្តើម......1
២. សកម្មភាព និងលទ្ធផលសម្រេចបាន......2
២.១. ការពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៧ ដែលត្រូវការសិក្សាសុវត្ថិភាព......3
២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧......3
២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៧......4
២.១.៣.បញ្ជីគម្រោងមូលនិធិរាជធានី ខេត្ត ឆ្នាំ២០១៧......5
២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង ឆ្នាំ២០១៧......5
២.២.១.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់......5
២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុក......6
២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្ត......6
២.៣. ការត្រួតពិនិត្យឯកសាររបាយការណ៍ និងការអនុវត្តសុវត្ថិភាពដីធ្លីរបស់គម្រោងក្រោយពេលដេញថ្លៃរួច ឆ្នាំ២០១៦......7
២.៤. ការពង្រឹងសមត្ថភាព......7
២.៥. សកម្មភាពពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ......7
២.៦. ការគាំទ្រ និងកិច្ចសហការ......8
៣. បញ្ហាប្រឈម......8
៤. ការសន្និដ្ឋាន......9
៥. អនុសាសន៍ និងសំណូមពរ......10
៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៨......11
៧. ឧបសម្ព័ន្ធ៖
៧.១.តារាងតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពគម្រោងឆ្នាំ២០១៧ និងការផ្តល់យោបល់បច្ចេកទេស
៧.២.បញ្ជីឈ្មោះមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
៧.៣.រូបថតសកម្មភាពក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច

## ១. សេចក្តីផ្តើម

ផែនការអនុវត្តដំណាក់កាលទី១(២០១១-២០១៤) ផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ឱ្យក្លាយជាស្ថាប័នអភិបាលកិច្ចមូលដ្ឋាន និងអភិវឌ្ឍមូលដ្ឋានយ៉ាងពិតប្រាកដ។ មូលដ្ឋានគ្រឹះសំខាន់ៗ ដូចជារចនាសម្ព័ន្ធ នីតិវិធី ប្រព័ន្ធ និងឧបករណ៍ជាច្រើនសម្រាប់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងវិញ និងបានផ្តល់ជាបង្អែកយ៉ាងរឹងមាំសម្រាប់ការបោះជំហានឆ្ពោះទៅមុខ។ មូលដ្ឋានគ្រឹះទាំងនេះបណ្តាលឱ្យផអ៣ទី១ ក្លាយជាកម្លាំងចលករមួយដ៏សំខាន់សម្រាប់ការងារកំណែទម្រង់ និងជាសនិទានកម្មដ៏សំខាន់ដែលនាំឱ្យរាជរដ្ឋាភិបាលបានសម្រេចចិត្តអនុវត្តដំណាក់កាលទី២(ផអ៣ទី២)តាមរយៈកិច្ចប្រជុំលើកទី១០ របស់ គ.ជ.អ.ប. កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ដែលចាប់ផ្តើមពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៧។ ចក្ខុវិស័យនៃផអ៣ទី២នេះ គឺ"*រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែល្អប្រសើរ កាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន* "។ ស្រដៀងគ្នានឹងផអ៣ទី១ដែរ ផអ៣ទី២ បានបន្តផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើរដ្ឋបាលក្រុង ស្រុក ប៉ុន្តែក៏មានការពាក់ព័ន្ធជាមួយនឹងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀតផងដែរ។ ទាក់ទងទៅនឹងភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិក្នុងក្របខណ្ឌផអ៣ទី២មិនអនុវត្តដោយអនុកម្មវិធីទៀតទេ។ ភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ គឺជាក្រសួងស្ថាប័នទាំងឡាយណាដែលមានការពាក់ព័ន្ធជាមួយការងារកំណែទម្រង់ ជាពិសេសការផ្ទេរមុខងារ និងធនធានក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយការផ្តួចផ្តើមសំដៅសម្រេចបានដោយជោគជ័យក្នុងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ចក្ខុវិស័យសម្រាប់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺការប្រើប្រាស់ធនធានទាំងអស់ដែលមានរួមទាំងមន្ត្រីរាជការស៊ីវិល បុគ្គលិកកិច្ចសន្យា ទាំងផ្នែកឯកជន និងអង្គការសង្គមស៊ីវិល។ ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅរាជធានី ខេត្ត គឺជាយន្តការថ្មីមួយទៀតនៃផអ៣ទី២ ដែលសង្ឃឹមថានឹងធានាបាននូវការរៀបចំវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពដែលមានលក្ខណៈឆ្លើយតបទៅនឹងសមិទ្ធផលទាំងប្រាំរបស់ផអ៣ទី២គឺ៖១). ការគ្រប់គ្រងកំណែទម្រង់ ២). គណនេយ្យភាពបែបប្រជាធិបតេយ្យ ៣). ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ៤). កាផ្ទេរមុខងារ និងធនធានក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន និង៥). វិមជ្ឈការហិរញ្ញវត្ថុ ។

កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលជាគោលនយោបាយដ៏មានសារៈសំខាន់ និងបានដាក់ចេញដោយរាជរដ្ឋាភិបាល ប្រកបដោយឆន្ទៈដ៏ច្បាស់លាស់ ក្នុងការលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព សមធម៌សង្គម និងគណនេយ្យភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត គឺជាសៀវភៅណែនាំដែលបរិយាយអំពីដំណាក់កាលទាំងអស់នៃការអនុវត្តគម្រោង ដោយចែកចេញជាជំពូកៗ ហើយក្នុងជំពូកនីមួយៗមានបែងចែកជាផ្នែកតូចៗទៀត។ គោលនយោបាយកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាផ្នែកមួយដែលមានសារៈសំខាន់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលហៅកាត់ថាសៀវភៅ(ភីម)និងបានបន្តទៅគម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត។ កិច្ចការពារសុវត្ថិភាព គឺជាឧបករណ៍សម្រាប់ការពារបរិស្ថាន និងធនធានធម្មជាតិ សិទ្ធិក្នុងការប្រើប្រាស់ដីធ្លី និងវិធានការការពារសុវត្ថិភាព ជនជាតិដើមភាគតិច ដែលអាចរងទទួលរងនូវផលប៉ះពាល់ពីការអនុវត្តគម្រោង។ ការងារនេះ បានអនុវត្តចាប់តាំងពីឆ្នាំ២០០៩មកម្ល៉េះ ដោយមានការកែតម្រូវតាមលិខិតណែនាំនានាជាបន្តបន្ទាប់។

កិច្ចការពារសុវត្ថិភាពជាយន្តការមួយត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ។ យន្តការមួយនេះ ត្រូវបានប្រើប្រាស់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងទាំងបីប្រភេទ ដែលតម្រូវឱ្យអ្នកអនុវត្តគម្រោងត្រូវតែមានការប្រុងប្រយ័ត្នជាមុនលើហានិភ័យដែលអាចកើតមានឡើងដោយសារការអនុវត្តគម្រោងលើកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងវិធានការការពារសុវត្ថិភាព

ជនជាតិដើមភាគតិច គោលបំណងសំខាន់នៃកិច្ចការពារសុវត្ថិភាពទាំងនេះ គឺបញ្ចៀសបាន ឬកាត់បន្ថយបានជាអប្បបរមា ឬក៏សម្រាលបន្ទុកនៃផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន ឬចំណាយសង្គម ចំពោះភាគីទីបី ឬពុំអើពើចំពោះក្រុមជនងាយរងគ្រោះ ដែលអាចទទួលរងឥទ្ធិពលពីការអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋាន។ ការងារនេះ បានក្លាយជាប្រធានបទមួយយ៉ាងសំខាន់សម្រាប់ការអនុវត្តគម្រោងទាំងអស់នៅថ្នាក់ក្រោមជាតិ ដែលលេខាធិការដ្ឋាន គ.ជ.អ.ប បានពិចារណាយ៉ាងល្អិតល្អន់លើដំណោះស្រាយបញ្ហាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចជាអាទិភាពសម្រាប់គ្រប់គម្រោងទាំងអស់។

## ២. សកម្មភាព និងលទ្ធផលសម្រេចបាន

ក្នុងឆ្នាំ២០១៧នេះ ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានអនុវត្តន៍តាមផែនការសកម្មភាព និងថវិកាដែលបានគ្រោងទុក ហើយសម្រេចបានលទ្ធផលមួយចំនួនមានដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់បំពេញការងាររបស់ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
- សម្របសម្រួលជាមួយនាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងខេត្ត ព្រមទាំងបានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងឆ្នាំ២០១៧ជារៀងរាល់ខែដែលថ្នាក់ក្រោមជាតិបានផ្ញើមក
- ចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដល់មន្ត្រីដែលទើបចូលបម្រើការងារថ្មីនៃគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសទៅថ្នាក់ក្រោមជាតិជំហានដំបូងមុនការអនុវត្តដេញថ្លៃគម្រោងលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសាររបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច
- ចុះត្រួតពិនិត្យ និងពង្រឹងការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសុវត្ថិភាពដីធ្លីជាក់ស្តែងនៅតាមបណ្តាឃុំ សង្កាត់ និងនៅទីតាំងគម្រោង ដោយជួបជាមួយមន្ត្រីពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ទីប្រឹក្សាពាក់ព័ន្ធគម្រោងថ្នាក់ខេត្ត ទីប្រឹក្សាក្រុង ទីប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង
- រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីតំបន់ងាយទទួលរងនូវផលប៉ះពាល់បរិស្ថាន និងបញ្ជីជនជាតិដើមភាគតិចថ្មីដែលទិន្នន័យចុងក្រោយទទួលបានពីខេត្តទាំង២៤ និងបានរៀបចំរបាយការណ៍សង្ខេបដាក់ជូនថ្នាក់ដឹកនាំអង្គភាពពិនិត្យ និងសម្រេចជាគោលការណ៍
- ចូលរួមសម្ភាសន៍ជ្រើសរើសមន្ត្រីការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៅថ្នាក់ជាតិ និងមន្ត្រីហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ខេត្ត
- ប្រជុំជាមួយក្រុមទីប្រឹក្សាក្រុមហ៊ុនMott McDonal នៃមូលនិធិអាកាសធាតុបៃតង(Green Climate Fund)ដែលចុះមកសិក្សាស្រាវជ្រាវពីភាពខ្វះចន្លោះក្នុងការទទួលបាននូវសេចក្តីសម្រេចទទួលមូលនិធិពី GCFសម្រាប់ការងារអភិវឌ្ឍន៍នៅលេខាធិការដ្ឋាន
- សម្របសម្រួលក្នុងវគ្គផ្សព្វផ្សាយផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់សៀវភៅកីមថ្មីដែលត្រូវប្រើប្រាស់នៅក្នុងឆ្នាំ២០១៨ ដល់មន្ត្រី និងទីប្រឹក្សានៅថ្នាក់ក្រោមជាតិដែលបានរៀបចំឡើងនៅខេត្តតាកែវ

- o បានចូលរួមប្រជុំជាមួយទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ីដែលមកធ្វើការស្វែងយល់ពីការងារអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងឃុំ សង្កាត់នៅមូលដ្ឋាន បញ្ហាប្រឈម និងដំណោះស្រាយដែលជួបប្រទះនៅថ្នាក់ក្រោមជាតិ
- o បានចូលរួមវាយតម្លៃការអនុវត្តមូលនិធិបន្សាំនឹងការប្រែប្រួលអកាសធាតុផ្អែកលើលទ្ធផលការអនុវត្តឆ្នាំ២០១៧លើកទីមួយនៅខេត្តបាត់ដំបងក្នុងស្រុករុក្ខគិរី គាស់ក្រឡ រតនមណ្ឌល សំពៅលូន និងភ្នំព្រឹក ដែលមានគម្រោងក្នុងឃុំចំនួន១០ដោយមានអ្នកចូលរួមសរុបចំនួន១៣៤រូបស្ត្រីចំនួន១០រូប លើកទីពីរនៅខេត្តតាកែវក្នុងស្រុកបាទី ស្រុកបូរីជលសារ និងក្រុងដូនកែវ មានគម្រោងក្នុងឃុំចំនួន៦គម្រោងដោយមានអ្នកចូលរួមសរុបចំនួន២០៣រូបស្ត្រីចំនួន៨២រូប។

**២.១.ការចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៧ ដែលតម្រូវការសិក្សាសុវត្ថិភាព ៖**

**២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៧ ៖**

គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៧ សរុបមានចំនួន **១៦៦៦** គម្រោងនៃ**១៥៣៧** ឃុំ សង្កាត់ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន **៦៦២**គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន**៤៤៣**គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន**៩៩**គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប **៦៤០**គម្រោង និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចមានចំនួនសរុប **៩៩**គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៤។ គម្រោងរាជធានីភ្នំពេញមិនមាននៅក្នុងបញ្ជីទេ ដោយសារមិនបានប្រើប្រាស់មូលនិធិឃុំ សង្កាត់របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ។

**រូបភាពទី១៖ ក្រាហ្វិចចំនួនឃុំសង្កាត់ និងចំនួនគម្រោងតម្រូវការសិក្សាសុវត្ថិភាព**




នៅក្នុងគម្រោងសរុបចំនួន**១៦៦៦**នេះ មានផ្លូវដីស ផ្លូវក្រួសក្រហម និងផ្លូវបេតុងអាមេចំនួន**១២៩៨**ខ្សែ ស្ពានចំនួន**៥០**កន្លែង ប្រព័ន្ធធារាសាស្ត្រមានប្រឡាយ និងទំនប់ចំនួន **១២៤**កន្លែង អណ្តូងស្នប់ និងស្រះជីកចំនួន**៤៦**កន្លែង សាលារៀនចំនួន**១៦**កន្លែង បង្គន់អនាម័យមាន**៣**កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹក សំណង់ទីទួលសុវត្ថិភាព និងផែសហគមន៍ចំនួន**៧២**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្ត។

**រូបភាពទី២៖ ក្រាហ្វិចឈ្មោះគម្រោងឃុំ សង្កាត់ និងចំនួនគម្រោង**




## ២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៧ ៖

គម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៧ មានចំនួនសរុប**២១១** គម្រោង នៃ១១៨ ក្រុង ស្រុក ក្នុងខេត្តចំនួន២០ ។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន **៩៧**គម្រោង តម្រូវការសិក្សាដីធ្លីមានចំនួន២២គម្រោង តម្រូវការសិក្សាជនជាតិដើមភាគតិចមាន១**២**គម្រោង។ ចំនួនគម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុប៩៧។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើង ។

**រូបភាពទី៣៖ ក្រាហ្វិចចំនួនក្រុង ស្រុក និងតម្រូវការសិក្សាសុវត្ថិភាព**




នៅក្នុងគម្រោងសរុបចំនួន**២១១**នេះ មានផ្លូវក្រួសក្រហម និងផ្លូវបេតុងអាមេរ៉ចំនួន**១០៨**ខ្សែ ស្ពានចំនួន**២**កន្លែង ប្រព័ន្ធធារាសាស្ត្រមានប្រឡាយ និងទំនប់ចំនួន **១៩**កន្លែង ស្រះទឹក**៤**កន្លែង ជួសជុលអគាររដ្ឋបាលចំនួន**១៤**កន្លែង បង្គន់មាន**២**កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹក ការកែលម្អសួនច្បារ ការជួសជុលរបងអាគារ ការចាក់សាបទីធ្លាសាធារណៈ ការសាងសង់ផែបណ្តែតទឹក ការគ្រប់គ្រងសំណល់ ការតបណ្តាញអគ្គីសនីសាធារណៈសរុបចំនួន**៥៧**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្ត។

**រូបភាពទី៤៖ ក្រាហ្វិចឈ្មោះគម្រោងក្រុង ស្រុក និងចំនួនគម្រោង**



### ២.១.៣.បញ្ជីគម្រោងមូលនិធិខេត្ត ឆ្នាំ២០១៧ ៖

គម្រោងមូលនិធិខេត្តដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៧សរុបមានចំនួន**១១៤**គម្រោងនៃគម្រោងដែលខេត្តចំនួន១១ផ្ញើមក ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន**៣៤**គម្រោង តម្រូវការសិក្សាដីធ្លីមាន១គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមានចំនួន**៧**គម្រោង។ គម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប**២៣**គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងរបស់ខេត្ត ។

**រូបភាពទី៥៖ ក្រាហ្វិចចំនួនគម្រោងខេត្ត និងតម្រូវការសិក្សាសុវត្ថិភាព**




នៅក្នុងគម្រោងសរុបចំនួន**១១៤**នេះ មានផ្លូវបេតុង ផ្លូវដីស និងផ្លូវក្រួសក្រហមចំនួន**៣៤**ខ្សែ ប្រព័ន្ធធារាសាស្ត្រមានប្រឡាយអមសងខាងផ្លូវចំនួន**២**គម្រោង ជួសជុលអគាររដ្ឋបាល សាលប្រជុំសាលាស្រុក អគាររដ្ឋបាលរោងឡាន និងឃ្លាំងចំនួន**៧១**កន្លែង និងផ្សេងៗដែលមានដាក់ស្លាកសញ្ញាចរាចរណ៍ ជួសជុលសួនច្បារ បំពាក់បង្គោលភ្លើង ការរៀបចំបិកឡៀផ្លូវ ការសាងសង់ស្ថានីយ៍បូមទឹក ការរៀបបណ្ដាញលូសងខាងផ្លូវ និងលូកាត់ផ្លូវ និងការរៀបចំកន្លែងចាក់សំរាមចំនួន**៧១**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្តន៍។

**រូបភាពទី៦៖ ក្រាហ្វិចឈ្មោះគម្រោងខេត្ត និងចំនួនគម្រោង**




## ២.២.ការពិនិត្យ និងការផ្ដល់យោបល់បច្ចេកទេសគម្រោង ឆ្នាំ២០១៧៖

### ២.២.១.ការពិនិត្យ និងការផ្ដល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ៖

បានពិនិត្យនិងផ្ដល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានចំនួនសរុប **៥៣៨**គម្រោង ស្មើនឹង**៨៤%**នៃគម្រោងសរុបចំនួន**៦៤០** និងផ្ដល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចសរុបចំនួន**៧៧**គម្រោង ស្មើនឹង**៧៨%**នៃចំនួន**៩៩**គម្រោង ដែលស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិច។

**រូបភាពទី៧៖ ក្រាហ្វិចចំនួនគម្រោងឃុំ សង្កាត់ និងភាគរយដែលបានពិនិត្យនិងផ្តល់យោបល់**




**២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៧៖**

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិក្រុង ស្រុក លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានដែលស្ថិតនៅក្នុងក្នុងបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួនសរុប **៥៩**គម្រោង ស្មើនឹង **៦៩%**នៃចំនួនសរុប**៨៦**គម្រោង និងរបាយការណ៍ការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន**៤**គម្រោង នៃ**១៣** គម្រោងស្មើនិង**៣១%**។

**រូបភាពទី៨៖ ក្រាហ្វិចចំនួនគម្រោងក្រុង ស្រុក និងភាគរយដែលបានពិនិត្យ**




**២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្តឆ្នាំ២០១៧៖**

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួន**១៣**គម្រោង ស្មើនឹង**៤៥%**នៃចំនួន**២៩**គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន**១០**គម្រោងស្មើ**៨៣%**នៃចំនួន **១២**គម្រោង។

**រូបភាពទី៩៖ ក្រាហ្វិចចំនួនគម្រោងខេត្ត និងភាគរយដែលបានពិនិត្យ**



## ២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃគម្រោងឆ្នាំ២០១៦ ៖

បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោងនៅទីចាត់ការផែនការ និងវិនិយោគខេត្ត ចំនួនប្រាំពីរខេត្ត ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ ក្នុងខេត្តទាំងប្រាំពីរនេះ បានត្រួតពិនិត្យគម្រោងសិក្សាដីធ្លីសរុបចំនួន**១០៨**គម្រោង ស្មើនឹង**៦៩**%នៃគម្រោងមូលនិធិឃុំ សង្កាត់ ត្រូវការសិក្សាដីធ្លីសរុបចំនួន**១៥៦**គម្រោង។ ដំណើរការនៃការត្រួតពិនិត្យឯកសារ និងរបាយការណ៍ដីធ្លីនេះ ធ្វើឡើងនៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងសាលាឃុំ សង្កាត់ ហើយផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះ និងនៅតាមទីតាំងគម្រោងបានជួបជាមួយប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង។ បន្ទាប់ពីបញ្ចប់រាល់ការពិនិត្យឯកសារ ក្រុមការងារបានប្រជុំឆ្លុះបញ្ចាំងដោយបង្ហាញពីលទ្ធផលដែលបានរកឃើញដល់នាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគ ព្រមទាំងមន្ត្រីទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងទីប្រឹក្សាខេត្តពាក់ព័ន្ធ ដើម្បីផ្តល់យោបល់លើចំណុចខ្វះខាតដែលជាមេរៀន និងបទពិសោធន៍សម្រាប់អនុវត្តន៍នៅឆ្នាំក្រោយៗទៀត។ តារាងខាងក្រោមបង្ហាញពីចំនួនឯកសាររបាយការណ៍សិក្សាដីធ្លី ដែលក្រុមការងារបានត្រួតពិនិត្យ។

**តារាងទី១៖ ចំនួនគម្រោងដែលសិក្សាដីធ្លីក្នុងឆ្នាំ២០១៦ និងភាគរយដែលបានចុះត្រួតពិនិត្យ**

| ល.រ | ឈ្មោះខេត្ត | គម្រោងសរុប | គម្រោង សិក្សាដីធ្លី | គម្រោងត្រូវបានពិនិត្យ | ចំនួន% |
|---|---|---|---|---|---|
| ១ | កំពង់ចាម | ១២០ | ៩ | ៩ | ១០០% |
| ២ | ត្បូងឃ្មុំ | ៦៩ | ១០ | ១០ | ១០០% |
| ៣ | ក្រចេះ | ៤៦ | ២៣ | ២២ | ៩៥% |
| ៤ | ស្ទឹងត្រែង | ៣៧ | ២៣ | ១៧ | ៧៧% |
| ៥ | ព្រះសីហនុ | ២៨ | ៦ | ៦ | ១០០% |
| ៦ | កំពត | ១០៣ | ៦០ | ២១ | ៣៥% |
| ៧ | តាកែវ | ១០៨ | ២៥ | ២៣ | ៩២% |
| **សរុប** | | **៥១១** | **១៥៦** | **១០៨** | **៦៩%** |

## ២.៤. ការពង្រឹងសមត្ថភាព៖

- បានចូលរួមក្នុងកិច្ចប្រជុំក្រុមបច្ចេកទេសសេចក្តីព្រាងបឋមនៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ នៅក្នុងផ្នែកកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចសម្រាប់ប្រើប្រាស់ឆ្នាំ២០១៨ ចំនួនពីរលើក ដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ នៅសាលប្រជុំខេត្តកំពង់ចាម ។

## ២.៥. សកម្មភាពពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ៖

- ថ្ងៃទី៧-៩ ខែកុម្ភៈ ឆ្នាំ២០១៧ នៅខេត្តបាត់ដំបង បានចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលបន្តដល់មន្ត្រីថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទើបជាប់អណត្តិថ្មីអំពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងសហគមន៍មូលដ្ឋានដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប មានអ្នកចូលរួមសរុបចំនួន៦៨រូបក្នុងនេះស្ត្រី១១រូប ដែលអញ្ជើញមកពីខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។
- ថ្ងៃទី១៣-១៧ ខែមីនា ឆ្នាំ២០១៧ នៅខេត្តកំពង់ធំ បានចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលបន្តដល់មន្ត្រីថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទើបជាប់អណត្តិថ្មីអំពីកិច្ចការពារ

សុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងសហគមន៍មូលដ្ឋានដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប មានអ្នកចូលរួមសរុបចំនួន៦៧រូបក្នុងនេះស្ត្រីចំនួន១០រូប ដែលអញ្ជើញមកពីខេត្តកំពង់ធំ ខេត្តព្រៃវែង និងខេត្តបាត់ដំបង។

- នៅខេត្តបន្ទាយមានជ័យថ្ងៃទី២០-២៤ ខែមីនា ២០១៧ បានចូលរួមសម្របសម្រួល និងបង្រៀនផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងជាមួយក្រុមការងារគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋានរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ស្រុក គណៈកម្មការលទ្ធកម្មស្រុក មន្ត្រីសម្របសម្រួលគម្រោង មន្ត្រីហិរញ្ញវត្ថុស្រុក អ្នកជំនួយការបច្ចេកទេសស្រុក និងទីប្រឹក្សា គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋានថ្នាក់ខេត្តដែលអញ្ជើញមកពី០៣ខេត្ត ក្នុងនោះរួមមាន៖ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តកំពង់ធំសរុបចំនួន៦៦រូបស្ត្រី៨រូប។
- ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៧ បានចូលរួមប្រជុំផ្តល់យោបល់ផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចជាមួយក្រុមការងារសវនកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាលប្រជុំលេខាធិការដ្ឋាន គ.ជ.អ.ប ដែលក្រុមនេះចុះមកធ្វើការស្វែងយល់ពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងខេត្ត ។
- នៅខេត្តកំពង់ចាមថ្ងៃទី២៧-២៩ ខែកញ្ញា ២០១៧ បានចូលរួមសម្របសម្រួល និងបង្រៀនផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងជាមួយក្រុមការងារគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋានរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត ស្រុក គណៈកម្មការលទ្ធកម្មស្រុក មន្ត្រីសម្របសម្រួលគម្រោង មន្ត្រីហិរញ្ញវត្ថុស្រុក អ្នកជំនួយការបច្ចេកទេសស្រុក និងទីប្រឹក្សារបស់គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋានថ្នាក់ខេត្តដែលអញ្ជើញមកពីខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តកំពង់ស្ពឺសរុបចំនួន១០០រូប។
- ថ្ងៃទី១៦-១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ បានចូលរួមសម្របសម្រួលក្នុងវគ្គផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ថ្មីសម្រាប់ប្រើប្រាស់នៅក្នុងឆ្នាំ២០១៨ នៅសាលប្រជុំសាលាខេត្តតាកែវ ដែលមាននាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីការិយាល័យផែនការ និងគាំទ្រមូលដ្ឋាន ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់ខេត្តសរុបចំនួន១២៩រូបស្ត្រីចំនួន៨រូប។

### ២.៦. ការគាំទ្រ និងកិច្ចសហការៈ

- ក្រុមការងារបានសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រីនៃទីចាត់ការផែនការ និងវិនិយោគខេត្តទាំង២៤ ដើម្បីពន្លឿនការសិក្សាកិច្ចការពារសុវត្ថិភាពបរិស្ថានដីធ្លី និងជនជាតិដើមភាគតិច ដើម្បីផ្ញើឯកសាររបាយការណ៍មកក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងឱ្យទាន់ពេលវេលាដេញថ្លៃ និងបានឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ។

## ៣. បញ្ហាប្រឈមនានា

ក្នុងឆ្នាំនេះក៏ដូចក្នុងឆ្នាំមុនដែរ ការសិក្សាតម្រូវការកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងនៅថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវ រហូតដល់ខែមេសាទើបមានខេត្តមួយចំនួនបានផ្ញើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមកក្រុមការងារសុវត្ថិភាព ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេស ដែលជាហេតុនាំឱ្យមានការពន្យាពេលការដេញថ្លៃគម្រោង មូលហេតុទាំងនេះ មកពីខេត្តទាំងនោះមានឧបករណ៍ សម្ភារៈ និងមធ្យោបាយចាស់ៗពេក និងខ្លះខូចមិន

អាចប្រើប្រាស់ក្នុងការសិក្សាគម្រោងបាន។ នៅថ្នាក់ក្រោមជាតិ ខេត្តមួយចំនួនបានធ្វើការសិក្សាផលប៉ះពាល់បរិស្ថាន និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច មុនពេលធ្វើតម្រូវការសិក្សាគម្រោង និងធ្វើផែនការគម្រោង ដែលខុសនឹងនីតិវិធីដែលមានចែងក្នុងសៀវភៅ(ភីម) នាំឱ្យមានការរៀបចំឯកសារម្តងហើយម្តងទៀត។ មិនទល់ពេលនេះ មានខេត្តខ្លះមិនទាន់បានបញ្ចប់១០០ភាគរយក្នុងការធ្វើឯកសារគម្រោងដែលតម្រូវការសិក្សាបរិស្ថាន និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចតាមផែនការដែលបានលើកឡើងនៅឡើយទេ។ បញ្ហាប្រឈមមួយចំនួន ដែលក្រុមការងារបានរកឃើញក្នុងការពិនិត្យឯកសារគម្រោង ដីធ្លី និងចុះទៅដល់ទីតាំងគម្រោងមានដូចខាងក្រោម៖

- បំពេញទម្រង់នានានៅតែមានភាពខ្វះចន្លោះច្រើន ពិសេសការគូរផែនទីអង្កេតដីធ្លីនៅមិនទាន់បានត្រឹមត្រូវនៅឡើយ
- នៅថ្នាក់ក្រោមជាតិមន្ត្រីទទួលបន្ទុកលើការងារផ្នែកបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងភាគច្រើនជាមន្ត្រីថ្មីដែលនៅមិនទាន់យល់ពីការសិក្សាសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងនៅឡើយ
- ឯកសារច្បាប់ដើមរបស់គម្រោងមួយចំនួនមិនបានរក្សាទុកនៅសាលាឃុំ សង្កាត់ក្រោយអនុវត្តគម្រោងចប់សព្វគ្រប់
- ការចុះគាំទ្រគម្រោងរបស់មន្ត្រីពុំសូវបានជិតដល់ដោយសារខ្វះមធ្យោបាយ និងថវិកា ព្រមទាំងការលើកទឹកចិត្តផងដែរ
- មន្ត្រីជំនាញរបស់មន្ទីរពាក់ព័ន្ធ និងជាមន្ត្រីបង្គោលបរិស្ថានមិនបានចូលរួមវិភាគផលប៉ះពាល់បរិស្ថានរបស់គម្រោង ដោយសារទីចាត់ការផែនការ និងវិនិយោគមិនមានថវិកាដោះស្រាយ និងផ្តល់មធ្យោបាយដល់មន្ត្រីជំនាញចុះទៅសិក្សាគម្រោង
- មធ្យោបាយដឹកជញ្ជូន និងសម្ភារះប្រើប្រាស់មានសភាពទ្រុឌទ្រោមប្រើមិនកើតជាការលំបាកសម្រាប់មន្ត្រីដែលទទួលបន្ទុកសិក្សាគម្រោងផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
- ដំណើរការពិនិត្យ និងបញ្ជាក់ឯកសារគម្រោងពីថ្នាក់ខេត្ត ស្រុក ដល់ឃុំ សង្កាត់មានភាពយឺតយូរ
- មានមន្ត្រីនិងទីប្រឹក្សាមិនគ្រប់គ្រាន់នៅក្នុងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ជួយបណ្តុះបណ្តាលបន្តដល់មន្ត្រី និងទីប្រឹក្សាថ្មីដែលនៅមិនទាន់បានទទួលការបណ្តុះបណ្តាលនៅឡើយ។

## ៤. ការសន្និដ្ឋាន

ក្នុងឆ្នាំ២០១៧នេះ ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចបានអនុវត្តការងារស្របទៅតាមផែនការសកម្មភាព ដែលបានគ្រោងទុក មានដូចជា៖ ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងរបាយការណ៍វិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោងមុនដេញថ្លៃ ត្រួតពិនិត្យឯកសាររបាយការណ៍ និងការអនុវត្តសុវត្ថិភាពដីធ្លីរបស់គម្រោងមូលនិធិឃុំសង្កាត់ គម្រោងក្រុង ស្រុក ឆ្នាំ២០១៦ដែលបានអនុវត្តរួចរាល់ ដើម្បីប្រាកដថាបាននៅថ្នាក់ក្រោមជាតិបានអនុវត្តន៍តាមការណែនាំ និងលិខិតបទដ្ឋាននានារបស់លេខាធិការដ្ឋាន។ តាមរយៈការចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនេះ ក្រុមការងារបានជួបជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្ត ស្រុក និងឃុំសង្កាត់ ព្រមទាំងចុះអង្កេតផ្ទាល់ដល់ទីតាំងគម្រោង និងបានជួបជាមួយប្រជាពលរដ្ឋ។ ខេត្តមួយចំនួនដែលក្រុមការងារបានចុះត្រួតពិនិត្យគម្រោងអនុវត្តន៍ក្នុងឆ្នាំ២០១៦ សង្កេតឃើញថា ខេត្តដែលធ្លាប់បានចុះត្រួតពិនិត្យក្នុងឆ្នាំកន្លងទៅមានការកែប្រែក្នុងកម្រិតបង្គួរ ។ ដោយឡែកខេត្តមួយចំនួនដែលមានការផ្លាស់ប្តូរមន្ត្រីជួយគាំទ្រគម្រោងជាញឹកញាប់ ក្រុមការងារបានរកឃើញមានការបំពេញឯកសារគម្រោងនៅតែមានភាពខ្វះចន្លោះច្រើនដដែល មានដូចជា៖ ការបំពេញទម្រង់ទី១ ទម្រង់ទី២ និងទម្រង់ទី១០មិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំ មានការមិនយកចិត្តទុកដាក់លើការចុះកាលបរិច្ឆេទចុះហត្ថលេខាលើទម្រង់ និងមិនបានជ្រើសរើសតម្រូវការសិក្សាគម្រោង ការបំពេញរបាយការណ៍បរិច្ចាគដីធ្លី

និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តឲ្យគម្រោង(ទម្រង់ទី២០.៩)បំពេញទិន្នន័យមិនបានត្រឹមត្រូវ និងចុះកាលបរិច្ឆេទដោយកុំព្យូទ័រទុកជាមុន បានរៀបចំរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្តឱ្យគម្រោង(ទម្រង់ទី២០.៩)មុនកិច្ចព្រមព្រៀងបរិច្ចាគ ការគូរផែនទីអង្កេតដីធ្លីនៅមិនទាន់បានត្រឹមត្រូវ មេឃុំបានបញ្ជាក់ និងបានចុះហត្ថលេខាប្រថាប់ត្រាមុនប្រជាពលរដ្ឋផ្តិតមេដៃព្រមព្រៀងនៅក្នុង(ទម្រង់ទី២០.៥) ការចុះកាលបរិច្ឆេទលើទម្រង់របាយការណ៍ដោយកុំព្យូទ័រទុកជាមុនលើទម្រង់របាយការណ៍ ការប្រជុំវិភាគផលប៉ះពាល់បរិស្ថានមានតែចំនួនក្រុមការងារមិនមានប្រជាពលរដ្ឋចូលរួមវិភាគ មិនបានចុះកាលបរិច្ឆេទលើទម្រង់ទី២០.៨ដែលជាបញ្ជីឈ្មោះអ្នកចូលរួមអង្កេតដីធ្លី មានឃុំសង្កាត់មួយចំនួនតូចបានចុះអង្កេតដីធ្លីមានចំនួនប្រជាពលរដ្ឋចូលរួមតែពីរបីគ្រួសារមិនបានបំពេញលេខសូន្យក្នុងប្រអប់ដែលទំនេរក្នុងតារាងលទ្ធកម្មដីធ្លី(ទម្រង់ទី២០.២) សរសេរកំណត់ហេតុប្រជុំផ្សព្វផ្សាយ និងប្រជុំពិភាក្សាព្រមព្រៀងរៀបចំមិនបានត្រឹមត្រូវ ការរៀបចំឯកសារគម្រោងមានបាត់ទម្រង់មួយចំនួន ការបំពេញទម្រង់របាយការណ៍វិភាគបរិស្ថានរបស់គម្រោងក្រុង ស្រុក និងគម្រោងខេត្តនៅមានការខ្វះចន្លោះច្រើន។ ជាមួយគ្នានឹងការបំពេញឯកសារខ្វះចន្លោះនេះ ខេត្តនីមួយៗជួបនូវបញ្ហាខ្វះឧបករណ៍សម្ភារៈប្រើប្រាស់សម្រាប់សិក្សាគម្រោង ខេត្តខ្លះមានមន្ត្រីមិនគ្រប់គ្រាន់ជួយគាំទ្រគម្រោង មានមន្ត្រី និងទីប្រឹក្សាមិនគ្រប់គ្រាន់នៅក្នុងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់បណ្តុះបណ្តាលបន្ត ពុំសូវមានកិច្ចសហការគ្នាល្អរវាងទីចាត់ការផែនការ និងវិនិយោគជាមួយមន្ទីរជំនាញពាក់ព័ន្ធនិងការអនុវត្តគម្រោង។ មានខេត្តខ្លះបានអនុវត្តន៍វិភាគផលប៉ះពាល់បរិស្ថាន និងសិក្សាដីធ្លីរបស់គម្រោងម្ចាស់ការដោយខ្លួនឯងជាបណ្តើរៗហើយ។

## ៥. អនុសាសន៍ និងសំណូមពរ

ដើម្បីពង្រឹងការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ និងដើម្បីឆ្លើយតបតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅភីម និងលិខិតណែនាំនានាលុះត្រាតែ៖

- បង្កើនការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធ ជាពិសេស ការតាមដាន ត្រួតពិនិត្យពីសំណាក់ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាពង្រឹងសមត្ថភាព ទាំងការរៀបចំទុកដាក់ឯកសារ និងការអនុវត្តជាក់ស្តែង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់ទីប្រឹក្សាក្រុង ស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត

- បង្កើនការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធក្នុងការត្រួតពិនិត្យឯកសារឡើងវិញមុននឹងអនុវត្តន៍ការដេញថ្លៃគម្រោង ចៀសវាងដេញថ្លៃគម្រោងរួចរាល់តែឯកសារគម្រោងមានលក្ខណៈមិនប្រក្រតីខុសពីការណែនាំ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះការសិក្សា ការរៀបចំឯកសារគម្រោងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា ព្រមទាំងបង្កើននូវការតាមដាន ត្រួតពិនិត្យពេលអនុវត្តន៍គម្រោង និងថែទាំលទ្ធផលគម្រោងឱ្យបានជាប់ជាប្រចាំ

- មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ត្រូវបង្កើនកិច្ចសហការគ្នាចុះតាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោងឱ្យបានជិតដល់

- មន្ត្រីគាំទ្រគម្រោងដែលទទួលខុសត្រូវនៅក្នុងឃុំសង្កាត់របស់ខ្លួន ត្រូវខិតខំស្វែងយល់ពីការសិក្សាសុវត្ថិភាពគម្រោងឲ្យស្ទាត់ជំនាញសម្រាប់ជួយគាំទ្រគម្រោង

- ខេត្តគួរពិចារណាពិនិត្យលទ្ធភាពបណ្តុះបណ្តាលដល់មន្ត្រីថ្មី និងទីប្រឹក្សាក្រុង ស្រុកពីកិច្ចការពារសុវត្ថិភាព បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៅដើមឆ្នាំមុនអនុវត្តន៍គម្រោង។
- ទីចាត់ការផែនការ និងវិនិយោគខេត្ត គួរបង្កើនកិច្ចសហការគ្នាល្អជាមួយមន្ទីរជំនាញពាក់ព័ន្ធក្នុងការបញ្ជាក់បច្ចេកទេសផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងមុនពេលដេញថ្លៃ។

## ៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៨

សកម្មភាពសំខាន់ៗសម្រាប់ធនុវត្តន៍នៅក្នុងឆ្នាំ២០១៨មានដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨ សម្រាប់ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
- បន្តបញ្ចប់ការរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិច ដោយធ្វើការទំនាក់ទំនងជាមួយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីបានប្រើប្រាស់បញ្ជីទាំងពីរនៅក្នុងឆ្នាំ២០១៨
- ជួយសម្របសម្រួលក្នុងវគ្គរំលឹកឡើងវិញស្តីពីគោលការណ៍ណែនាំការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង តាមការអញ្ជើញរបស់ថ្នាក់ក្រោមជាតិ និងគម្រោងដាច់ដោយឡែកក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសាររបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងខេត្តមុនដេញថ្លៃគម្រោង
- ចុះតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងនិងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចរបស់គម្រោងនៅថ្នាក់ក្រោមជាតិដោយចុះត្រួតពិនិត្យជាក់ស្តែងនៅទីតាំងគម្រោង
- ចុះត្រួតពិនិត្យឯកសាររបាយការណ៍ និងការអនុវត្តសុវត្ថិភាពដីធ្លីនៃគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក ឆ្នាំ២០១៧
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០១៨ស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងក្របខណ្ឌគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត
- ចូលរួមសម្របសម្រួលជាមួយមន្ត្រី និងទីប្រឹក្សារបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ និងអង្គភាពនានាចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានាដល់មន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ
- រៀបចំរបាយកាយណ៍រីកចម្រើនប្រចាំខែ និងប្រចាំឆ្នាំជាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប.។

**រៀបចំដោយ**
**ក្រុមការងារកិច្ចការពារសុវត្ថិភាព ប.ដ.ជ**
**នៃលេខាធិការដ្ឋាន គ.ជ.អ.ប.**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី
លេខ: ៦៩៧/អ.គ.គ.ក

ថ្ងៃ ៨ កើត ខែបុស្ស ឆ្នាំរកា ព.ស ២៥៦១.
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧

**សូមគោរពជូន**

**ឯកឧត្តមអនុប្រធានប្រតិបត្តិ នៃលេខាធិការដ្ឋាន គ.ជ.អ.ប.**

**កម្មវត្ថុ** ៖ របាយការណ៍សង្ខេបស្តីពីលទ្ធផលការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ប្រចាំឆ្នាំ២០១៧ ។

**យោង** ៖ ផែនការសកម្មភាពរបស់ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចឆ្នាំ ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា ការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចជាផ្នែកមួយដ៏សំខាន់បំផុតនៅក្នុងការអនុវត្តគម្រោងវិនិយោគនៅថ្នាក់ក្រោមជាតិ ដែលទាមទារនូវការយកចិត្តទុកដាក់ពីគ្រប់អ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ហើយតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់មន្ត្រីរបស់ទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីការិយាល័យគាំទ្រឃុំ សង្កាត់ នៅថ្នាក់ក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោងផងដែរ។

ក្នុងឆ្នាំ២០១៧នេះ ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដែលមានមន្ត្រី និងទីប្រឹក្សាបានខិតខំបំពេញការងាររបស់ខ្លួនតាមផែនការសកម្មភាព និងថវិកាដែលបានលើកឡើងនៅដើមឆ្នាំដោយយកចិត្តទុកដាក់ និងមានការទទួលខុសត្រូវខ្ពស់ រហូតទទួលបានលទ្ធផលការងារចម្បងៗមានដូចខាងក្រោម៖

១. ក្រុមការងារបានសម្របសម្រួលជាមួយនាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត ទីប្រឹក្សាអភិវឌ្ឍន៍ និងកសាងសមត្ថភាពខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក គម្រោងខេត្ត និងបានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងឆ្នាំ២០១៧ ជារៀងរាល់ខែដែលថ្នាក់ក្រោមជាតិបានសិក្សាមុននឹងអនុវត្តន៍គម្រោង។ សង្ខេបជារួមមានបង្ហាញជូនដូចខាងក្រោម៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៧ សរុបមានចំនួន ១៦៦៦ គម្រោងនៃ១៥៣៧ ឃុំ សង្កាត់ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន ៦៦២គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន៤៤៣គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន៩៩គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប៦៤០គម្រោង និងគម្រោងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចមានចំនួនសរុប ៩៩គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៤។ គម្រោងរាជធានីភ្នំពេញមិនមាននៅក្នុងបញ្ជីទេ ដោយសារមិនបានប្រើប្រាស់មូលនិធិឃុំ សង្កាត់របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ។

មហាវិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). M inistry of Interior. Tel: (855-23) 720 061 / 720 038

ខ).គម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៧ មានចំនួនសរុប២១១ គម្រោងនៃ១១៨ ក្រុង ស្រុក ក្នុងខេត្តចំនួន២០ ។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបមានចំនួន ៩៧ គម្រោង តម្រូវការសិក្សាដីធ្លីមានចំនួន២២គម្រោង តម្រូវការសិក្សាជនជាតិដើមភាគតិចមាន១២ គម្រោង។ ចំនួនគម្រោងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមានចំនួន៩៧។

គ).គម្រោងមូលនិធិខេត្តដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៧សរុបមានចំនួន១១៤គម្រោងនៃ គម្រោងដែលខេត្តចំនួន១១ផ្ញើមក ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបមានចំនួន៣៤គម្រោង តម្រូវ ការសិក្សាដីធ្លីមាន១គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុប មានចំនួនចំនួន៧គម្រោង។ គម្រោងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមាន ចំនួន២៣គម្រោង។

២. បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោង រាជធានី ខេត្ត មុនដេញថ្លៃគម្រោងលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានដែលស្ថិតក្នុងបញ្ជីតំបន់ងាយ ទទួលរងផលប៉ះពាល់បរិស្ថាន និងតំបន់ជនជាតិដើមភាគតិច ដែលខេត្តទាំងអស់បានផ្ញើមកក្រុមការងារ។ គម្រោង ដែលបានពិនិត្យ និងផ្តល់យោបល់បច្ចេកទេសមានដូចខាងក្រោមៈ

ក). គម្រោងមូលនិធិឃុំ សង្កាត់ ផ្នែកបរិស្ថានសរុបមានចំនួន ៥៤១គម្រោង ស្មើនឹង៨៥%នៃចំនួនសរុប ៦៤០គម្រោង និងវិធានការការពារជនជាតិដើមភាគតិចពិនិត្យបានចំនួន៧៧គម្រោង ស្មើនឹង ៧៨%នៃ ចំនួន៩៩គម្រោង ។ ក្នុងនេះមានគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុLGCCIIផងដែរ។

ខ).គម្រោងមូលនិធិក្រុង ស្រុក ផ្នែកបរិស្ថានបានចំនួនសរុប ៥៩គម្រោង ស្មើនឹង៦៩%នៃចំនួនសរុប៨៦ គម្រោង និងពិនិត្យវិធានការការពារជនជាតិដើមភាគតិចបានចំនួន ៤គម្រោង ស្មើនឹង៣១%នៃចំនួន ១៣ គម្រោង ។

គ).បានពិនិត្យបរិស្ថានគម្រោងមូលនិធិខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានពិនិត្យ បានចំនួនសរុប ១៥គម្រោង ស្មើនឹង៤៨%នៃចំនួនសរុប ៣១គម្រោង និងពិនិត្យគម្រោងជនជាតិដើម ភាគតិចបានចំនួន ១០គម្រោង ស្មើ៨៣%នៃចំនួន ១២គម្រោង។

